# ការសម្ភាសរបស់អ៊ុំស្រី ជីន កុន

**កៈ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ាវ** **ខៈ អ្នកទទួលការសម្ភាសឈ្មោះ ជីន កុន។**

## ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី ជីន កុន

អ៊ុំស្រីជីន កុនមានអាយុ៥៥ឆ្នាំនៅក្នុងឆ្នាំ២០២០ មានកូន៣នាក់ ស្រី៣នាក់ មានទីលំនៅបច្ចុប្បន្ននៅភូមិរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាទាំងអស់និងត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរ មានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់និងបានដឹងជាពិសេសប្រវត្តិរបស់អ៊ុំផ្ទាល់ទុកអោយកូនៗចៅៗរបស់អ៊ុំបានស្គាល់បានដឹងពីប្រវត្តិរបស់ដែរអ៊ុំរៀបរាប់ជាមួយខ្ញុំចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសមួយនិងទៅក្នុងវេបសាយសាលាទេអ៊ុំខ្ញុំនិងដាក់ការសម្ភាសហ្នឹងទៅក្នុងវេបសាយរបស់សាលាចឹងបាសណាស់?

ខៈ ចាស!

កៈ ដើម្បីទុកអោយកូនចៅរបស់អ៊ុំចឹងហាសណាស់អ៊ុំ?

ខៈ ចាស!

កៈ បាទអ៊ុំចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី២៧ខែ៧ឆ្នាំ២០២០ហើយការសម្ភាសទាំងអស់និងគឺធ្វើឡើងនៅភូមិទួលរកា ឃុំរអាង អើស្រុកកំពង់សៀម ខេត្តកំពង់ចាមចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំទាំងត្រកូលតាមបញ្ជីជាតិម៉ងឈ្មោះអីគេអ៊ុំ?

ខៈ ឈ្មោះជីន កុន។

កៈ ជីន កុន?

ខៈ ចាស! កុន។

កៈ អ៊ំជីនកុនណោះយាយ?

ខៈ ចាស!

កៈ ជីនកុនចុះមានឈ្មោះហៅក្រៅអត់អ៊ុំ?

ខៈ ចាស!

កៈ មានឈ្មោះហៅក្រៅអត់?

ខៈ យកអត់ផង។

កៈ អើលក្ខណៈថាឪពុកម្ដាយមាននរណាគេហៅឈ្មោះអ៊ុំអីផ្សេងអត់នៅក្មេងអ៊ុំ?

ខៈ ឪពុកឈ្មោះពីបញ្ជីជាតិពីមុនមកគាត់ដាក់ឈ្មោះខុនរួចដល់ណោះគេអត់ហៅខុនតែកុនៗ។

កៈ អ៊ំចឹងហៅឈ្មោះជីនកុនចឹងម៉ងទៅ?

ខៈ ចាស!

កៈ អ៊ំបាទអ៊ុំចុះអើអ៊ុំគិតថាអើចាំមួយភ្លេតអ៊ុំអ៊ុំគិតថាអើអ៊ុំសព្វថ្ងៃអ៊ុំអាយុប៉ុន្មានអ៊ុំ?

ខៈ អាយុហាប្រាំ។

កៈ អ៊ំអាយុហាសិបប្រាំឆ្នាំណោះអ៊ុំណោះ?

ខៈ ចាស!

កៈ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំចាំទេអ៊ុំ?

ខៈ អត់ចាំផង។

កៈ អ៊ំចុះអើឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះអ៊ុំចាំអត់?

ខ៖ ចាំឆ្នាំមមី។

ក៖ ឆ្នាំមមីណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ ចុះអ៊ុំកើតលក្ខណៈថាអ៊ុំកើតនៅណាអ៊ុំស្រុកកំណើតដែរអ៊ុំកើតម៉ង?

ខ៖ កើតនៅហ្នឹង!

ក៖ នៅស្រុកហ្នឹងម៉ង?

ខ៖ នៅទួលរកា។

ក៖ អូ៎ភូមិទួលរកាហ្នឹងម៉ង?

ខ៖ ចាស!

ក៖ ចុះអ៊ុំមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់អ៊ុំ?

ខ៖ ប្រាំនាក់។

ក៖ ចុះអ៊ុំបងគេរឺមួយក៏ម៉េច?

ខ៖ ខ្ញុំទីបីទេ។

ក៖ ទីបីណោះអ៊ុំ?

ខ៖ ចាស!

ក៖ ចុះបងៗគាត់ឈ្មោះអីគេខ្លះទៅអ៊ុំ?

ខ៖ ឈ្មោះស្រី។

ក៖ នេះហោស?

ខ៖ ចាស! នេះ។

កៈ អ៊ុំចុះទីពីរអ៊ុំ?

ខៈ មកកេត។

កៈ អ៊ុំបន្ទាប់មកអ៊ុំកុន?

ខៈ ចាស!

កៈ ចុះអើ..?

ខៈ បន្ទាប់មកវុន។

កៈ វុនហើយ..?

ខៈ វិន។

កៈ វិនពៅគេណេះអ៊ុំ?

ខៈ ចាស!

កៈ ចុះអើបង..?

ខៈ ផ្ទះហ្នឹង!

កៈ អ៊ុំផ្ទះហ្នឹងហោស?

ខៈ ចាស!ពៅគេហ្នឹង!

កៈ អ៊ុំអ៊ុំនៅជាមួយពៅហោស?

ខៈ ទេណោះវាទៅនៅអ៊ីស្រែហោសប៉ុនវាទុកផ្ទះចោលនៅទីហ្នឹង!

កៈ រួចចុះអ៊ុំនៅណា?

ខៈ ខ្ញុំនេះផ្ទះ។

កៈ អ៊ុំផ្ទះនេះហោស?

ខ៖ ចាស!

ក៖ អ៊ុំបីផ្ទះហ្នឹងបងប្អូនអ៊ុំទាំងបី?

ខ៖ ចាស! ពីរនិងហើយផ្ទះបងខ្ញុំមួយ។

ក៖ អ៊ុំសុទ្ធតែបងប្អូន?

ខ៖ ចាស!

ក៖ អ៊ុំបាទអ៊ុំចុះអើអ៊ុំគិតថាអើបងរបស់អ៊ុំបងធំគាត់ធ្វើអីគេអ៊ុំ?

ខ៖ បងខ្ញុំនោះហោស?

ក៖ បាទ!

ខ៖ មានធ្វើអីនៅតែផ្ទះហ្នឹង!

ក៖ អ៊ុំចុះកូនចៅគាត់ធ្វើអីគេទៅ?

ខ៖ កូនចៅរកត្រីតិចតួច។

ក៖ អ៊ុំគាត់មានកូនប៉ុន្មាននាក់អ៊ុំ?

ខ៖ បងខ្ញុំណុងហោស?

ក៖ បាទអ៊ុំ!

ខ៖ មានប៉ុន្មាននាក់ទេស្រីកូនស្រីឯងប៉ុន្មាននាក់ភ្លេចហើយស្រី។

ក៖ អត់អីទេបើគាត់..?

ខ៖ ស្រីហោសកូនស្រីឯងប៉ុន្មាននាក់គាត់សួរដល់បងអីហ្នឹងហាស!

ក៖ អត់អីទេបើសិនជាចុះទីពីរហោសអ៊ុំ?

ខ៖ ទីពីរ។

កៈ ទីពីរនៅណា?

ខៈ ទីពីរនៅអ៊ីណោះខេត្តព្រះវិហារហោស!

កៈ អ្ហូ!

ខៈ កូនពីរនាក់។

កៈ អ្ហូចុះអ៊ុំ?

ខៈ ខ្ញុំកូនបីនាក់។

កៈ បីនាក់ណោះអ៊ុំរួចចុះទីបួន?

ខៈ ទីបួនកូនពីរ។

កៈ កូនពីរចឹងគាត់នៅណា?

ខៈ នៅព្រះវិហារដែរ។

កៈ អ្ហូគាត់នៅបានឆ្ងាយហាសណរអ៊ុំ?

ខៈ ចាស! ពីរនាក់ណុងនៅណុង។

កៈ អ្ហូចុះពៅ?

ខៈ ពៅហ្នឹងកូនបួន។

កៈ គាត់នៅណា?

ខៈ នៅស្រែហោស!

កៈ អ្ហូថាផ្ទះគាត់នៅហ្នឹង?

ខៈ ចាស! នៅធ្វើផ្ទះនៅស្រែហ្នឹងដែរ។

កៈ អ្ហូគាត់ធ្វើអីគេ?

ខ៖ ខាងធ្វើចំការស្រែហ្នឹងស្រែ..។

ក៖ ចុះអ្នកនៅព្រះវិហារគាត់ធ្វើអីគេ?

ខ៖ ធ្វើស្រែធ្វើអីដែរធ្វើចិញ្ចឹមគោចិញ្ចឹមក្របី។

ក៖ អូ៎!

ខ៖ ធ្វើសំណង់ធ្វើអី។

ក៖ គាត់យកគ្រួសារនៅណុងម៉ងហោស?

ខ៖ ចាស!

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាអ៊ុំធ្លាប់មានជាអនុស្សាវរីយ៍ជាមួយបងប្អូនអ៊ុំកាលនៅក្មេងៗទេធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់ទេអ៊ុំ?

ខ៖ អត់ផង។

ក៖ លក្ខណៈថាដូចធ្វើទៅស្រែទៅចំការអីជាមួយគ្នាអីចឹងហាសណាស់?

ខ៖ ចាស! ធ្វើស្រែធ្វើអីចឹងជាមួយទាអីខ្ញុំហ្នឹង!

ក៖ អូ៎!

ខ៖ ម៉ែអីនិងធ្វើស្រែស្ទូងដកហ្នឹង!

ក៖ បាទអ៊ុំប៉ុន្តែគ្រាន់ថាឥឡូវហ្នឹងយើងនៅបែកគ្នាទាំងអស់ណេះអ៊ុំ?

ខ៖ ចាស! នៅបែកគ្នាទាំងអស់។

ក៖ តែគ្រាន់ថាបីនាក់បងប្អូននៅជិតៗគ្នាទេ?

ខ៖ ចាស!

ក៖ តែពីរនាក់ទេ?

ខ៖ ចាស!

ក៖ គាត់មានគ្រួសារទៅនៅនោះ?

ខ៖ នៅព្រះវិហារ។

ក៖ ឪពុករបស់អ៊ុំឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះជីន ជីនញ៉ឹក។

ក៖ ញ៉ឹបជីនហីអ៊ុំ?

ខ៖ ចាស! ញ៉ឹកជីន។

ក៖ ញ៉ឹបជីនរួចចុះម្ដាយវិញ?

ខ៖ ហ្នឹងឈ្មោះញ៉ឹបហ្នឹងហាសម្ដាយខ្ញុំហ្នឹងហី?

ក៖ បាទ!

ខ៖ ឈ្មោះញ៉ឹប។

ក៖ អូ៎!

ខ៖ ឪពុកឈ្មោះជីន។

ក៖ ម្ដាយឈ្មោះញ៉ឹបឪពុកឈ្មោះជីន?

ខ៖ ចាស!

ក៖ អូ៎បាទចុះអើឪពុកម្ដាយគាត់អ្នកស្រុកនៅហ្នឹងតើហី?

ខ៖ ចាស! នៅហ្នឹងនៅទួលរកាហ្នឹងបើទាខ្ញុំនោះគាត់នៅព្រៃកយួន។

ក៖ អូ៎ម៉េចចឹង?

ខ៖ គាត់មកដណ្ដឹងនៅហ្នឹង!

កៈ អូ៎ដល់ពេលហើយរួចចុះចឹងអ៊ុំមកនៅខាងប្តីទេ?

ខៈ អូ៎ឪពុកស្វូរនិយាយប្តីខ្ញុំហោស?

កៈ និយាយៗឪពុករបស់អ៊ុំ?

ខៈ ឪពុកហោស?

កៈ បាទ!

ខៈ គាត់នៅហ្នឹងតើ!

កៈ គាត់នៅហ្នឹង?

ខៈ ចាស! គាត់មកយកប្រពន្ធនៅទួលរកាហ្នឹង!

កៈ អូ៎!

ខៈ ទៅម៉ែឪគាត់អ្នកគៀនជ្រៃ។

កៈ អូ៎បាទអ៊ុំបាទឪពុករបស់អ៊ុំកាលគាត់នៅរស់គាត់ស្លាប់នៅអ៊ុំ?

ខៈ ស្លាប់អស់ហើយ!

កៈ កាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅចិញ្ចឹមក្រុមគ្រួសារ?

ខៈ គាត់ធ្វើស្រែធ្វើចំការហ្នឹងហាស!

កៈ អូ៎តាំងពី..?

ខៈ ចាស! តាំងពី..។

កៈ តាំងពីអើយមកម៉ង?

ខៈ ចាស! តាំងពីអើយមកគ្មានធ្វើអីទេ។

កៈ អូ៎បាទអ៊ុំបាទចុះអើគាត់កាចរឺមួយក៏ស្លូតអ៊ុំ?

ខ៖ គាត់មិនសូវជាកាចប៉ុន្មានទេគាត់ស្លូតដែរ។

ក៖ អូ៎បាទអ៊ុំបាទចុះអើម្ដាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅអ៊ុំ?

ខ៖ គាត់អត់ធ្វើអីផងធ្វើតែស្រែចំការតិចតួចទៅ។

ក៖ អូ៎ចឹងគាត់ធ្វើជាមួយគ្នាចឹងហាសណោះធ្វើប្រាំងធ្វើអីហាសណោះ?

ខ៖ ចាស!

ក៖ អូ៎!

ខ៖ ហើយទូលលក់។

ក៖ គាត់លក់អីគេទៅ?

ខ៖ លក់ត្រកួនទៅលក់អីប្រហុកអីយើងទិញប្រហុកអីយកទៅលក់ចឹងទៅ។

ក៖ អូ៎!

ខ៖ ត្រកួនអី។

ក៖ បាទអ៊ុំបាទចុះអើដូចជាអ៊ុំធ្លាប់មានជាសាច់រឿងអនុស្សាវរីយ៍អីដែរអ៊ុំនៅជាមួយឪពុកម្ដាយកាលនៅក្មេងៗទេធ្លាប់មានជារឿងដើរអីដូចលក្ខណៈទៅស្រែឬមួយក៏ធ្វើស្រែអីជាមួយគ្នាធ្លាប់មានតើណោះអ៊ុំណោះ?

ខ៖ ធ្លាប់តែដើរទៅធ្វើស្រែណុង។

ក៖ អូ៎!

ខ៖ ជាមួយគាត់ជាមួយអីហ្នឹង!

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាអើឪពុករបស់អ៊ុំធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ុំទេ?

ខ៖ គាត់អត់ដែរប្រាប់ផង។

ក៖ អូ៎គាត់អត់ដែរនិយាយអីទេណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ ចុះម្ដាយ?

ខ៖ ម្ដាយក៏អត់ដែរ។

ក៖ ម្ដាយអត់ដែរនិយាយអីទេណោះអ៊ុំណោះ?

ខ៖ ចាស! អត់ដែរម៉ែខ្ញុំអត់ចេះមាត់។

ក៖ អ៊ំុចុះយាយតាខាងឪពុកអ៊ុំស្គាល់ឈ្មោះគាត់ទេ?

ខ៖ ខ្ញុំអត់ស្គាល់ផង។

ក៖ អ៊ុំចុះយាយតាខាងម្ដាយ?

ខ៖ ឈ្មោះយាយធឿង។

ក៖ យាយធឿង?

ខ៖ ឪពុកឈ្មោះអីទេខ្ញុំអត់ស្គាល់។

ក៖ អ៊ុំម្ដាយហ្នឹងឈ្មោះយាយធឿង?

ខ៖ ចាស!

ក៖ ប៉ុន្ដែបើឪពុកអត់ស្គាល់ទេ?

ខ៖ តាទូចទេយ៉ាងតាទូច។

ក៖ តាទូចហោសប៉ុន្ដែបើថាឪពុកម្ដាយខាងឪពុកអត់ស្គាល់ទាំងអស់?

ខ៖ ចាស!

ក៖ អ៊ុំអ៊ុំកើតអត់ទាន់ហោស?

ខ៖ ចាស!

កៈ ប៉ុន្តែ..?

ខៈ គាត់មិនដឹងដែរប្រាប់ផងខ្ញុំអត់ចាំផង។

កៈ អ៊ូប៉ុន្តែគ្រាន់ថាពួកគាត់សុទ្ធតែអ្នកនៅគៀនជ្រៃហ្នឹងទាំងអស់?

ខៈ ចាស!

កៈ អ៊ូបាទអ៊ីបាទចុះអ៊ីមកនៅទួលរកាអស់រយះពេលប៉ុន្មានឆ្នាំហើយអ៊ី?

ខៈ សាមសិបប្រាំឆ្នាំហើយ!

កៈ អ៊ូយូរហើយណេះអ៊ីណេះការជាមួយប្ដីនិងនៅហ្នឹងម៉ងហោស?

ខៈ ចាស!

កៈ បាទអ៊ីបាទចុះអ៊ីមានបងប្អូនកូនចៅណាដែរទៅរស់នៅក្រៅប្រទេសអត់អ៊ី?

ខៈ អត់ផង។

កៈ នៅថៃនៅវៀតណាមអីអត់មានដែរ?

ខៈ អត់ទេ។

កៈ ចុះបើសិនជាជៀសពីកំពង់ចាមមាននៅភ្នំពេញនៅអីណា?

ខៈ អ៊ូនៅភ្នំពេញកូនបងស្រី។

កៈ អ៊ូកូនអ៊ីហោស?

ខៈ ចាស!

កៈ អ៊ូនៅតែភ្នំពេញតើហី?

ខៈ ចាស!

កៈ អត់មាននៅខេត្តផ្សេងទៀតណាហី?

ខ៖ អត់ទេចាស! នៅតែភ្នំពេញហ្នឹងកូនស្រីតែមួយ។

ក៖ អ៊ំបាទអ៊ុំចុះអើស្វាមីរបស់អ៊ុំឈ្មោះអីគេទៅអ៊ុំ?

ខ៖ ឈ្មោះតុងហេង។

ក៖ តុងហេង?

ខ៖ ចាស! តុងហេង។

ក៖ គាត់ឥឡូវគាត់នៅណាទៅអ៊ុំ?

ខ៖ ទៅរត់ម៉ូតូឌុប។

ក៖ អ៊ំគាត់អ្នករត់ម៉ូតូឌុបនៅណានៅកំពង់ចាមហោសអ៊ុំ?

ខ៖ ចាស!

ក៖ ល្ងាចឡើងបានគាត់មកវិញចឹងទៅ?

ខ៖ ចាស! ល្ងាចមកវិញ។

ក៖ តែអ៊ុំការអស់ប៉ុន្មានសាមសិបប្រាំឆ្នាំហើយណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ អ៊ំចុះអើអ៊ុំមានកូនប៉ុន្មាននាក់បីនាក់ហីអ៊ុំ?

ខ៖ កូនបី។

ក៖ តែកូនទីមួយនៅណាទៅ?

ខ៖ ទីមួយនៅភ្នំពេញណុង។

ក៖ អ៊ំគាត់ធ្វើអីគេគាត់មានគ្រួសារនៅណុង?

ខ៖ ចាស! មានធ្វើរោងចក្រ។

កៈ នៅជាមួយគ្រួសារគាត់ទៅ?

ខៈ ចាស!

កៈ អ៊ំចុះទីពីរអ៊ុំ?

ខៈ ទីពីរនេះនៅកំពង់ចាមនេះនៅធ្វើការរោងចក្រដែរ។

កៈ ស្រីដែរ?

ខៈ ចាស!

កៈ ចុះពៅគេ?

ខៈ ពៅគេណោះមីចាប់គ្រប់..។

កៈ អ៊ំបាទអ៊ុំបាទចុះអើចៅនិងចៅកូនទីប៉ុន្មាន?

ខៈ ទីពីរ។

កៈ កូនទីពីរហោសចឹងមានន័យថាគាត់ទុកចៅអោយអ៊ុំមើលនៅហ្នឹងណោះ?

ខៈ ចាស!

កៈ ហើយគាត់ទៅធ្វើការជាមួយប្ដីប្រពន្ធគាត់ទៅតែគាត់មកនិងវិញឬមួយក៏គាត់នៅកំពង់ចាមម៉ង?

ខៈ ដេកនៅណុង។

កៈ អ៊ំទាល់តែសៅរ៍អាទិត្យបានគាត់មកវិញចឹងទៅ?

ខៈ សៅរ៍អាទិត្យបានមកលេង។

កៈ បាទអ៊ុំ!

ខៈ ជួនមិនដឹងមក។

កៈ អ៎ូ!

ខៈ អាទិត្យម្សិលមិញមិនមកផងថាធ្វើការ។

កៈ អ៎ូបាទអ៊ុំបាទគាត់ថែមម៉ោងថែមអីចឹងហាសណេះអ៊ុំណេះ?

ខៈ ហ្នឹងហើយ!

កៈ បាទអ៊ុំចុះអ៊ុំគិតអើអ៊ុំការអស់រយះពេលប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ សាមប្រាំហើយហីតាំងពីម្ដែ៉ប្អូនម៉េស?

កៈ សាមសិបប្រាំឆ្នាំហោសម្ដែ៉ប្អូនឥឡូវអ៊ុំ..?

ខៈ ហាប្រាំ។

កៈ ហាប្រាំម្ដែ៉ប្អូនវាសាមសិបប្រាំមួយ?

ខៈ សាមសិបប្រាំមួយហើយ!

កៈ វាខ្វង់ប៉ុណ្ណឹងអ៊ុំចុះអើពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍និងគិតថាឪពុកម្ដាយជាអ្នករៀបចំអោយយើងឬមួយក៏អើយើងជាអ្នកចិត្តចង់រៀបដោយខ្លួនឯង?

ខៈ ឪពុកម្ដាយរៀបចំអោយ។

កៈ ពេលនិងយើងស្គាល់គ្នាពីមុននៅអ៊ុំ?

ខៈ អត់ផង។

កៈ អត់ដែរស្គាល់គ្នាទេណេះ?

ខៈ ចាស!

កៈ អ៎ូចុះពេលហ្នឹងយើងបានថ្លៃបណ្ណាការប៉ុន្មានទៅអ៊ុំ?

ខៈ ជំនាន់ណុងមិនដឹងបានប៉ុន្មានផងមួយម៉ឺនពីរម៉ឺន។

កៈ អូ៎!

ខៈ ជំនាន់ដាច់អាពតមក។

កៈ អូ៎បាទអ៊ុំបាទចុះអ៊ុំការនៅឆ្នាំប៉ែត្រជាងណោះអ៊ុំណោះ?

ខ ចាស!

កៈ អូ៎បាទអ៊ុំចុះអើអ៊ុំអាចសុំសួរទាក់ទងពីជំនាន់លុនណុលអ៊ុំទាន់ណោះអ៊ុំណោះ?

ខៈ ខ្ញុំដូចទាន់នៅកុមារប្រហែលប៉ុន្មានខែទេនេះរអាងលើយើងនេះ។

កៈ លុនណុលហោសអ៊ុំ?

ខៈ ចាស!ណុងជំនាន់អាពតហ្នឹងហី?

កៈ អត់ទេលុនណុល..?

ខៈ អត់ទេអត់ទាន់ទេជំនាន់ណុងហោស!

កៈ អូ៎!

ខៈ ទាន់ជំនាន់អាពតទេ។

កៈ ចូលប៉ុលពតម៉ងហោស?

ខៈ ចាស!អាពតគេយកធ្វើកុមារចូលដែរ។

កៈ អូ៎ចឹងអ៊ុំនៅកុមារហោស?

ខៈ ចាស!

កៈ ប៉ុន្តែគេជំលាសយើងទៅណាទៅ?

ខៈ ដូចអត់មានជំលាសទៅណាផងខ្ញុំធ្វើនៅរអាងលើនេះឃើញដាក់នៅរអាងលើ។

កៈ អូ៎!

ខ៖ ខ្ញុំហ្នឹងហាស!

ក៖ បាទអ៊ុំបាទចុះគេអោយយើងធ្វើអីគេទៅអ៊ុំនៅហ្នឹង?

ខ៖ ខ្ញុំចូលដឹងកាលណុងដឹងតែនៅមនុស្សជុំៗប៉ុនមិនដឹងធ្វើការខាងអីភ្លេចទៅហើយ!

ក៖ អូ៎!

ខ៖ អត់បានឃើញទៅធ្វើការអីណាផងឃើញតែទៅដេកជាមួយគេហើយក៏ខ្ញុំចង់ទៅអើកាលណុងដូចខ្ញុំចង់ទៅខ្លួនឯងចេះមិនដឹងដូចគេអត់រើសខ្ញុំភ្លេចហើយចាស! ចឹងនៅដេកនៅនេះផ្ទះនៅរអាងលើណុងហោសផ្ទះនេះណុងហោសចាសរួចខ្ញុំលេងលួចរត់តាមអូ៎សំរូតតាមដើមត្របែកមកជាមួយទាខ្ញុំនៅរអាងលើណុងរួចទៅគេស្តីអោយដូចឆ្កែអត់ដឹងអីសោះខ្ញុំនៅតូចហោស!

ក៖ ម៉េចចឹង?

ខ៖ ខ្ញុំនៅតូច។

ក៖ ម៉េចបានគេស្តីអោយយើង?

ខ៖ យើងលួចរត់មកដេកជាមួយឪពុកម្តាយយើងនេះ។

ក៖ អូ៎!

ខ៖ ចាស! គេអត់អោយមកអើមិនដឹងធ្វើការខាងអីផងខ្ញុំភ្លេចដែរខ្ញុំអត់ដឹងសោះចាសហ្នឹងហាសកុមារតូចៗហ្នឹងហាស!

ក៖ អូ៎គ្រាន់គេប្រមូលទៅគេអត់ទាន់អោយយើងធ្វើអីទេ?

ខ៖ ចាស!

ក៖ ប៉ុន្តែអ៊ុំគេអត់អោយចាំចាបចាំអីទេហោស?

ខ៖ ទេអត់ឃើញបានចាំចាបចាំអីផងឃើញចឹងហោសខ្ញុំវាភ្លេចទៅណុងហាស!

ក៖ អូ៎!

ខ៖ អើចិញ្ចាំកន្ត្រាំងខែតកន្ត្រាំងអីហ្នឹងហាស!

ក៖ ប៉ុន្តែរបប..?

ខ៖ ប៉ុន្តែចូលអត់ចូលយូរទេ។

ក៖ ចុះរបបអាហារយើងម៉េចទៅអ៊ុំចាំអត់?

ខ៖ ស៊ីបបរនិងឡើងរាវគឃ្លោកបួនប្រាំស្លាបព្រា។

ក៖ អូ៎បាទ!

ខ៖ កូរដូចគ្នា។

ក៖ បាទអ៊ុំបាទចុះអើយើងមានឈឺយើងអីតើអ៊ុំ?

ខ៖ ឈឺក្បាលឈឺអីតើដែរ។

ក៖ ចុះយើងធ្វើម៉េចទៅចឹងយើងទៅរកថ្នាំរកអីគេ?

ខ៖ ចាស! ប្រាប់គេទៅគេទិញថ្នាំអោយលេបទៅ។

ក៖ អូ៎!

ខ៖ ថ្នាំឈឺក្បាលអី។

ក៖ បាទអ៊ុំបាទរួចចុះអើពេលដែរចឹងទៅយើងអត់មានធ្វើអីយើងអត់ដឹងថាយើងធ្វើអីផងចឹង?

ខ៖ ខ្ញុំអត់ដឹងថាធ្វើអីធ្វើឃើញដឹងថាដេកនៅជុំគ្នានៅរអាងលើ។

ក៖ អូ៎!

ខ៖ អាធ្វើការវាភ្លេចទៅអត់ចាំសោះចឹងអត់ចាំខ្ញុំភ្លេចទៅហើយចាស!

ក៖ អូ៎!

ខ៖ ចាស! នៅក្មេងវានៅតូចៗពេកចាស!

កៈ បាទអ៊ុំបាទរួចចុះបងប្អូនទៅទាំងអស់គ្នាទៅ?

ខៈ ខ្ញុំកាលណុងដូចចូលតែឯងបងប្អូនដូចមិនដឹងគេបែកទៅណាមកណាអីនោះបងខ្ញុំនោះគេធ្វើនៅអីណោះនៅអីពង្រហោសនៅជាមួយអាផានណុងហាស!

កៈ អូ៎!

ខៈ បងខ្ញុំបងបង្អស់ណុងហាស!

កៈ បាទអ៊ុំបាទរួចចុះអើចឹងឪពុកម្ដាយទៅណុងដែរ?

ខៈ ឪពុកម្ដាយគាត់នៅអាលែងផ្ទះនៅរអាងលើណុងជិតកុមារណុងហាស!

កៈ ចឹងអ៊ុំរកឧស្សាហ៍លួចទៅដេក?

ខៈ ឧស្សាហ៍លួចទៅដេក។

កៈ រួចឪពុកម្ដាយគាត់អត់ថាអីទេ?

ខៈ គាត់ថាដែរ។

កៈ តែដោយសារយើងក្មេង?

ខៈ ព្រលឹមឡើងមកវិញគេស្ដីអោយទៅ។

កៈ អូ៎រួចចុះអ៊ុំគិតថាចឹងអើពេលដែរចឹងយើងអត់ដឹងថាយើងធ្វើអីចឹងយើងអត់ដឹងថាយើងពិបាករឺមួយក៏អត់ទេ?

ខៈ ចាស! អត់ដឹងសោះកាលណុងដឹងតែទៅដេកជាមួយក្រុមមិនដឹងធ្វើការអីផងខ្ញុំភ្លេច។

កៈ អូ៎!

ខៈ ដឹងតែទៅដេកជាមួយជុំគ្នាមនុស្សឡើងណៃនផ្ទះរួចព្រលប់ឡើងរត់ចុះតាមដើមត្របែកណុងមក។

កៈ អូ៎!

ខ៖ ចាស! អោយចាំចាបហ្នឹងហើយ!

ក៖ អូ៎!

ខ៖ តែខ្ញុំភ្លេចអាធ្វើការនេះហ្នឹងហើយចាំតែអាលែងនេះអាដេកជុំគ្នាលួចរត់ស្រមូតតាមដើមត្របែកមកដេកផ្ទះហ្នឹង!

ក៖ អូ៎បាទអ៊ុំបាទចុះទាក់ទងពីចឹងពេលដាច់ប៉ុពតវិញអ៊ុំធ្វើអីទៅពេលណុងចាំនៅ?

ខ៖ ដាច់ប៉ុលពតណុង។

ក៖ បាទ!

ខ៖ ដាច់ប៉ុលពតណុងមកនៅជាមួយម៉ែនិងធ្វើស្រែធ្វើប្រាំងហ្នឹង!

ក៖ អូ៎ចុះអើអ៊ុំគិតថាចឹងនៅពេលដែរធ្វើស្រែធ្វើប្រាំងរួមមែនទេអ៊ុំ?

ខ៖ ទេធ្វើឯកជនហ្នឹង!

ក៖ អូ៎!

ខ៖ ដាច់ប៉ុលពតមក។

ក៖ ដាច់ប៉ុលពតគ្រាន់គេអោយធ្វើរួមសិនណោះអត់ទេ?

ខ៖ នេះមិនដឹងធ្វើអីទេនេះរួមចឹងហើយច្រូតស្រូវរួចចែកស្រូវគ្នាដាក់ជង្រុកហោសសាមគ្គីហើយចឹងហោស!

ក៖ អូ៎ប៉ុន្តែពិបាកអត់ពេលហ្នឹង?

ខ៖ ពិបាកហាសឈ្លើងតៀមរត់ចង់ងាប់ខ្លាចគោងកគេគោងកឯង!

ក៖ ពេលណុងនៅប៉ុណ្ណាទៅ?

ខ៖ ខ្ញុំដឹងអាយុប៉ុន្មានទេប៉ុនកាលណុងនេះខ្ញុំភ្លេចហើយជាងដប់ឆ្នាំហើយយ៉ាង។

ក៖ អូ៎រួចចុះអើនៅពេលដែរចឹងយើងរហូតទាល់តែយើងបានធ្វើស្រែខ្លួនឯង?

ខ៖ ចាស! ខ្ញុំធ្វើស្រែខ្លួនឯងជាមួយម៉ែអីហ្នឹងមុខពង្រណុង។

ក៖ អាហ្នឹងបានយើងរៀងស្រួលបន្តិចណោះអ៊ំណោះ?

ខ៖ ចាស!

ក៖ រួចចុះអើពេលណាដែរពេលណុងនៅមានទាហ៊ានប៉ុលពតនៅឡើយតើហីឬមួយក៏អត់អស់ហើយ?

ខ៖ នៅទេហីកាលណុងហីក៏អីខ្ញុំវាភ្លេចហើយនេះ។

ក៖ គេចាប់យើងធ្វើទាហ៊ានធ្វើអីហីចាប់មនុស្សប្រុសចាប់អីធ្វើទាហ៊ាន?

ខ៖ ចាស! បែបកាលណុងចាប់មនុស្សប្រុសណុង។

ក៖ អូ៎!

ខ៖ កាលណុង។

ក៖ បាទអ៊ុំចុះអ៊ុំគិតថាចឹងសំរាប់ដូចជាពេលណាដែរយើងគិតថាយើងសប្បាយយើងធូរធារយើងអីចឹងហាសអ៊ុំ?

ខ៖ ទាល់តែមានប្តីណុងបានរៀងធូរធារតិច។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាចឹងទាក់ទងពីអើរៀនវិញអ៊ុំធលាប់បានរៀនពីមុនអត់អ៊ុំ?

ខ៖ អត់ចេះអត់បានរៀនផង។

ក៖ ម៉េចចឹងអ៊ុំ?

ខ៖ អត់ចេះផងណុងបើជំនាន់អាពតណុងមិនបានរៀនផង។

ក៖ មិនប៉ុលពតក៏អត់បានរៀនដែរណោះ?

ខ៖ ចាស!

ក៖ អូ៎ចុះទាក់ទងពីអើអ៊ុំមានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់ចឹងអ៊ុំ?

ខ៖ អត់មានផង។

ក៖ អូ៎អត់មានដែរ?

ខ៖ ចាស!

ក៖ អូ៎ប៉ុន្តែស្រែចំការអ៊ុំធ្លាប់ធ្វើ?

ខ៖ ធ្វើជាមួយម៉ែឪហ្នឹង!

ក៖ ជាទូទៅនៅស្រែអ៊ុំធ្វើអីទៅអ៊ុំ?

ខ៖ ចាស!

ក៖ នៅស្រែអ៊ុំធ្វើអីគេទៅ?

ខ៖ ដកស្ទូងណុងហាស!

ក៖ ច្រូតកាត់ដកស្ទូង?

ខ៖ ចាស!

ក៖ ភ្ជួររាស់អីចឹងហាសណោះ?

ខ៖ ចាស!

ក៖ អូ៎ចុះចំការចំការអ៊ុំធ្លាប់ធ្វើទេ?

ខ៖ ចំការខ្ញុំមិនដែរធ្វើផងខ្ញុំអត់មានចំការធ្វើផងធ្វើតែស្រែដកស្ទូងណុង។

ក៖ អូ៎!

ខ៖ រួចពីចឹងទៅដើរលក់ទៅ។

ក៖ កាលណុងនៅណា?

ខ៖ លក់គ្រកូនលក់អីទៅនៅហ្នឹង!

កៈ នៅហ្នឹងហាសណេះ?

ខៈ ចាស!

កៈ អ៊ូបាទអ៊ីចុះអ៊ីគិតថាលក់ដូរអ៊ីធ្លាប់លក់ដូរទេអ៊ី?

ខៈ លក់ត្រកួនលក់អីទៅទៅស្រែទៅលុកប្រហុកទិញប្រហុកគេយកដូរអង្ករដូរអីទៅដូរស្រូវទៅ។

កៈ អ៊ូ!

ខៈ ត្រសក់អីមកលក់ទៅឡើងក្រិចចង្កេះក្រោកមិនទាំងរួចផង។

កៈ ម៉េចចឹងអ៊ី?

ខៈ ធ្វើត្រសក់លើកត្រសក់ឡើងក្រិចចង្កេះ។

កៈ អ៊ូធ្ងន់ពេកហោសអ៊ី?

ខៈ ចាស!

កៈ អ៊ូបាទអ៊ីចុះអ៊ីគិតថាចឹងដូចជាចិញ្ចឹមសត្វអ៊ីធ្លាប់ចិញ្ចឹមសត្វពីមុនទេអ៊ីមាន់ ទា ជ្រូក គោក្របី?

ខៈ ធ្លាប់។

កៈ អ៊ូ!

ខៈ ចិញ្ចឹម។

កៈ អ៊ីចិញ្ចឹមអីគេទៅ?

ខៈ ជ្រូក។

កៈ ជ្រូកហោស?

ខៈ ចាស!

កៈ ចុះត្រី?

ខៈ ត្រី។

កៈ គោ ក្របីអីអ៊ុំធ្លាប់ចិញ្ចឹមអត់?

ខៈ ក្របីធ្លាប់បើត្រីអត់ផង។

កៈ អត់ទេណេះ?

ខៈ ចាស!

កៈ យើងចិញ្ចឹមលក្ខណៈជាលក់តិចតួចតើហីអ៊ុំហោស?

ខៈ ចិញ្ចឹមគោហោស?

កៈ បាទ!

ខៈ អត់ហើយធនាគារអត់មានផងលក់អស់ហើយ!

កៈ ប៉ុន្តែកាលពីមុន..?

ខៈ មួយពីរអីច្រើនណុងហាសកាលពីមុនឥឡូវលក់យូរយានហើយ!

កៈ អូ៎!

ខៈ ឥឡូវគ្មានស្អីទេ។

កៈ ចុះទាក់ទងពីតាំងពីក្មេងរហូតមកដល់ឥឡូវការងារអីគេខ្លះដែរអ៊ុំធ្លាប់ធ្វើទៅអ៊ុំ?

ខៈ មានធ្វើអីទេធ្លាប់ធ្វើតែស្រែហើយលក់ដូរហ្នឹង!

កៈ ចឹងហោសអ៊ុំ?

ខៈ មិនបានទៅធ្វើអីផងចាស!

កៈ អូ៎!

ខ៖ លក់ដូរតិចតួច។

ក៖ ចុះអេី..?

ខ៖ ហេីយស៊ីឈ្នួលគេហ្នឹង!

ក៖ បាទអ៊ុំបាទចុះអេីទាក់ទងពីអេីឥឡូវអ៊ុំឈប់ធ្វេីហេីយណេះអ៊ុំ?

ខ៖ ឥឡូវឈឺវាចេះតែឈឺអត់ទៅធ្វេីផងមេីលចៅ។

ក៖ មេីលចៅ?

ខ៖ ចាស!

ក៖ កូនៗគាត់ចេះតែអោយនៅមេីលចឹងទៅគាត់ផ្តល់លុយផ្តល់អីអោយ?

ខ៖ ចាស!

ក៖ អូ៎បាទអ៊ុំចុះអ៊ុំគិតថាចឹងទាក់ទងពីជីវិតរបស់អ៊ុំគិតថាមានការផ្លាស់ប្តូរអីគេខ្លះអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវកាលអ៊ុំនៅជាមួយឪពុកម្តាយជីវិតម៉េចទៅដល់ពេលរហូតមកដល់ឥឡូវជីវិតម៉េចទៅអ៊ុំ?

ខ៖ ឥឡូវវារៀងនៅមានប្តីទៅនៅរៀងស្រួលជាងនៅពីក្មេង។

ក៖ អូ៎!

ខ៖ វារៀងធូរធារតិច។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាឥឡូវទាំងសុខភាពជីវភាពក្រុមគ្រួសារម៉េចដែរអ៊ុំឥឡូវ?

ខ៖ បានតែមួយគ្រប់គ្រាន់ហ្នឹងគ្រាន់សល់ទេ។

ក៖ ចឹងហោស?

ខ៖ ចាស!

ក៖ អូ៎ប្តីរបស់អ៊ុំចេះតែទៅរត់ឌុបទៅ?

ខ៖ ចាស!

ក៖ ព្រលឹមទៅល្ងាចមកវិញទៅ?

ខ៖ ចាស!

ក៖ អូ៎!

ខ៖ គ្មានឈប់ទេ។

ក៖ បាទអ៊ុំ!

ខ៖ ឈឺម៉េចក៏ចេះតែទៅដែរ។

ក៖ ប៉ុន្តែគាត់រកបានដែរតើអ៊ុំហេស?

ខ៖ ពីរម៉ឺនទៅបីម៉ឺនទៅជួនមួយម៉ឺនទៅ។

ក៖ អូ៎រកបានតិចដែរចឹង?

ខ៖ ចាស!

ក៖ ចុះអ៊ុំគិតថាចឹងសំរាប់ដូចជាម្ហូបអីដែរអ៊ុំចូលចិត្តហូបអ៊ុំ?

ខ៖ ម្ហូបត្រីហ្នឹងហាស!

ក៖ ត្រីភាគច្រើនណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ សាច់អីអត់សូវចូលចិត្តប៉ុន្មានទេ?

ខ៖ ចាស! ម្តងមួយយាមសាច់។

ក៖ បាទអ៊ុំបាទចុះទាក់ទងពីល្បែងប្រជាប្រិយ៍អ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីទេអ៊ុំពីមុនដូចជាលាក់កន្សែង បោះអង្គុញ ចោលឈូង?

ខ៖ ចាស! លេងតើ!

ក៖ កាលណុងយើងលេងដែរណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ អូ៎បាទអ៊ុំបាទចុះអើច្រៀងរាំអ៊ុំចូលចិត្តអត់អ៊ុំ?

ខ៖ មិនដឹងចេះផង។

ក៖ អូ៎អ៊ុំអត់ចេះទេណោះ?

ខ៖ ចាស!

ក៖ ចុះល្ខោនយីកេអាយ៉ៃអ៊ុំចូលចិត្តទេអ៊ុំ?

ខ៖ ចូលចិត្តប៉ុនគេបើកទៅស្តាប់ទៅ។

ក៖ អូ៎!

ខ៖ ប៉ុនអោយចេះអត់ចេះទេចេះរាំតិចតួចណុងមើលគេទៅ។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាធិមឥឡូវអ៊ុំសុំសិល្ប៏នៅ?

ខ៖ នៅ។

ក៖ នៅទេណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖អូ៎បាទអ៊ុំបាទចអ៊ុំគិតថាអ៊ុំមាននរណាគេមួយនៅក្នុងក្រុមគ្រួសារចេះលេងឧបករណ៍ភ្លេងទេអ៊ុំ?

ខ៖ អត់មានផង។

ក៖ អត់មានទេណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ អ៊ុំភ្លេងខ្មែរ ភ្លេងសៀម ពិនពាតអីក៏អត់ដែរណោះអ៊ុំណោះ?

ខ៖ ចាស!

ក៖ អ៊ុំបាទអ៊ុំបាទចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាអ៊ុំកាលអ៊ុំនៅជាមួយឪពុកម្ដាយ?

ខ៖ ផ្ទះតូច។

ក៖ តែនៅហ្នឹងដែរ?

ខ៖ នៅហ្នឹងដីទីហ្នឹងហាសដីហ្នឹងហាស!

ក៖ នៅនេះទើបលើកក្រោយតើហីអ៊ុំ?

ខ៖ ចាស! នេះកូនទើបលើកក្រោយផ្ទះគាត់តូចទេ។

ក៖ អ៊ុំចុះអ៊ុំគិតថាដូចជាចឹងកាលផ្ទះគាត់និងជាផ្ទះលក្ខណៈបែបណា?

ខ៖ ផ្ទះ..។

ក៖ សង្កសី?

ខ៖ មួយខ្នងផ្ទះមួយខ្នងផ្ទះគាត់។

ក៖ សង្កសីហោស?

ខ៖ ចាស!

ក៖ មែនប្រកស្លឹកណាហីអ៊ុំ?

ខ៖ ប្រកដែក។

ក៖ ប្រកដែកដែរ?

ខ៖ ចាស!

កៈ ដល់ពេលពេលណាបានអានេះគាត់ចែកដីអោយ..?

ខៈ គាត់ខូចនៅផ្ទះណុងអស់ហើយ!

កៈ ប៉ុន្តែគាត់ចែកដីចែកអីអោយ?

ខៈ ចាស! ហ្នឹងហាសគាត់ចែកដីហ្នឹងហាសអានេះកូនលើកសារក្រោយ។

កៈ អូ៎!

ខៈ ផ្ទះគាត់ណោះអោយទៅអើក្មួយនៅស្រែហោសនៅពង្រហោសអោយទៅចៅចៅគាត់។

កៈ បាទអ៊ុំបាទដល់ពេលអ៊ុំមកលើកផ្ទះក្រោយនេះដែរទៅ?

ខៈ ចាស! ខ្ញុំទើបលើកក្រោយ។

កៈ អូ៎បាទអ៊ុំចុះអ៊ុំគិតថាអើដូចជាចឹងផ្ទះនិងនរណាគេចាអ្នកសាងសងជួសជុលវាអ៊ុំយើងជួលគេណោះអ៊ុំ?

ខៈ ជួលគេជួលជាង។

កៈ ប៉ុន្តែ..?

ខៈ កាលពីខ្ញុំមានប្ដីដំបូងមកផ្ទះនៅអឺគៀនជ្រៃណោះផ្ទះសងតូច។

កៈ អូ៎!

ខៈ ដល់ពេលបានកូនមួយកូនពីរបានទិញផ្ទះគេពីណុងមកមួយខ្នងប្រកដែកដែរមកនៅទីហ្នឹង!

កៈ បាទអ៊ុំ!

ខៈ មកនៅទីហ្នឹងបានប៉ុន្មានឆ្នាំរួចទើបបានមានលុយនេះលើកផ្ទះប៉ុណ្ណឹង!

កៈ អូ៎បាទអ៊ុំ!

ខៈ ពីរបីតំនរល្មមបានផ្ទះប៉ុណ្ណឹងនៅ។

កៈ អ៊ុំរួចចុះអ៊ុំគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារអ៊ុំចេះធ្វើផ្ទះអត់អ៊ុំ?

ខៈ ផ្ទះផ្ទះអត់ផង។

កៈ អត់មានទេណេះអ៊ុំណេះ?

ខៈ ចាស!

កៈ អ៊ុំបាទអ៊ុំចុះអ៊ុំគិតថាដូចជាអើឪពុកម្ដាយរបស់អ៊ុំគាត់ធ្លាប់បង្រៀនពីជំនាញអីមួយទៅអ៊ុំទេ?

ខៈ គាត់អត់ដែរបង្រៀនអីផង។

កៈ អត់ដែរទេណេះអ៊ុំណេះ?

ខៈ ចាស!

កៈ អ៊ុំចឹងភាគច្រើនអ៊ុំចេះធ្វើទេស្រែចំការ?

ខៈ ចាស!

កៈ អ៊ុំបាទអ៊ុំបាទចុះអើទាក់ទងពីការនៅពីតូចអ៊ុំធ្លាប់មានគោលបំណងរឺមួយក៏គិតជាមួយមិត្តភក្ដិថាធំឡើងអ៊ុំចង់ធ្វើអីមួយអ៊ុំធ្លាប់គិតពីមុនទេអ៊ុំ?

ខៈ អត់ដែរផង។

កៈ អត់ដែរគិតទេណេះអ៊ុំ?

ខៈ ចាស!

កៈ អ៊ុំចុះអ៊ុំគិតថាជីវភាពសព្វថ្ងៃឥឡូវម៉េចដែរអ៊ុំជាមួយប្ដីជាមួយចៅៗ?

ខៈ ឥឡូវវារៀងធូរធារតិច។

កៈ ធូរជាងមុនតិចណេះអ៊ុំណេះ?

ខៈ ចាស!

កៈ អ៎ូដោយសារតែប្តីទៅរកប៉ុន្តែអ៊ុំ..?

ខៈ ចាស!

កៈ នៅផ្ទះតើហី?

ខៈ ចាស!

កៈ ដោយសារអ៊ុំឈឺដែរអីដែរ?

ខៈ ឈឺដែរ។

កៈ អ៎ូហើយកូនចេះតែផ្តល់តិចតក់អោយខ្លះទៅ?

ខៈ ចាស! ផ្តល់តិចៗងោយចាយទៅ។

កៈ អ៎ូដោយសារកូនពួកគាត់យ៉ាប់ដែរណេះឬមួយក៏ម៉េច?

ខៈ ចាស! យ៉ាប់ដែរមិនមានផ្ទះនៅផងនៅជាមួយខ្ញុំហ្នឹង!

កៈ ចឹងហោស?

ខៈ ចាស!

កៈ កូនណានៅជាមួយអ៊ុំ?

ខៈ ហ្នឹងហាសឪពុកមីហ្នឹងទីពីរ។

កៈ ផ្ទះនៅកំពង់ចាមហ្នឹងហោស?

ខៈ ចាស! ជួលផ្ទះគេនៅកំពង់ចាមហ្នឹង!

កៈ ដល់ពេលសៅរ៏អាទិត្យគាត់មកចឹងទៅ?

ខៈ ចាស!

កៈ ដល់ពេលច័ន្ទសុក្រគាត់ទៅជួលផ្ទះពីរនាក់ប្តីប្រពន្ធនៅកំពង់ចាម?

ខ៖ ចាស! ខ្ញិលអោយមកនៅណុងម៉ងទៅចុះឡើងៗ។

ក៖ គាត់អើគាត់លក្ខណៈពីរនាក់ប្តីប្រពន្ធធ្វើការនៅរោងចក្រទាំងពីរនាក់?

ខ៖ ចាស! ធ្វើរោងចក្រទាំងពីរមុនពីឆ្នាំអើត្រីវាទើបលក់ប៉ុន្មានខែបួនប្រាំខែហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ រួចទៅខ្ញុំអោយទៅធ្វើរោងចក្រទៅវាគ្មានវាអត់ចំណេញទេចិញ្ចឹមត្រី។

ក៖ ពីរនាក់ប្តីប្រពន្ធបានប្រាំប្រាំមួយរយចឹងទៅណេះ?

ខ៖ មិនដល់ទេបានបួនរយប្រាំរយអី។

ក៖ បានគ្រាន់តែទប់ៗអ៊ុំហាសណេះ?

ខ៖ ចាស!

ក៖ ចកូនចៅអោយអីប៉ុន្តែរាល់ថ្ងៃអ៊ុំនៅជាមួយចៅៗប៉ុន្មាននាក់អ៊ុំ?

ខ៖ ពីរហ្នឹង!

ក៖ ពីរហើយហ្នឹងយាយតាពីរទៀតទៅ?

ខ៖ ចាស!

ក៖ អូ៎បាទអ៊ុំបាទចឹងខ្ញុំមានសំនួរចុងក្រោយមួយអ៊ុំបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយហាសអ៊ុំអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្តាំផ្ញើរទៅពួកគាត់ថាលក្ខណៈដូចជាចង់អោយពួកគាត់ខំប្រឹងរៀនដើម្បីមានអនាគត់ល្អកាលយើងអ៊ុំអ៊ុំអត់សូវបានរៀនច្រើនចឹងយើងអត់សូវមានការងារល្អអីចឹងហាណេះ?

ខ៖ ចាស! អោយក្មេងជំនាន់ក្រោយនិងអោយគេគេប្រាជ្ញាជាងក្មេងជំនាន់មុនហើយបានរៀនចេះដឹង។

ក៖ បាទអ៊ុំបាទប៉ុន្តែចៅៗ?

ខ៖ ចាស!

ក៖ អ៊ុំតែងតែទូន្មានព្រានប្រដៅគាត់រាល់ថ្ងៃហាសណេះអ៊ុំ?

ខ៖ ចាស!

ក៖ បាទអ៊ុំចុះអ៊ុំធ្លាប់អើដូចជាប្រាប់ពួកគាត់ដូចជាទូន្មានពួកគាត់អោយពួកគាត់ជៀសវៀងពីអំពើដែរអត់ល្អក្នុងសង្គមដូចជក់គ្រឿងញៀនដូចអី..?

ខ៖ ប្រាប់ប្រដែរប្រដៅរាល់តែថ្ងៃ។

ក៖ កូនចៅអ៊ុំណេះ?

ខ៖ ចាស!

ក៖ អ្ហូ!

ខ៖ ក្មេងវានៅធ្វើចឹង។

ក៖ បាទអ៊ុំបាទ!

ខ៖ ប្រដៅវាអត់ស្តាប់ផង។

ក៖ បាទ! ចុះអ៊ុំធ្លាប់ទូន្មានព្រានប្រដៅពួកគាត់អោយដើរតាមផ្លូវដែរអ៊ុំមានគិតគោលបំណងពីមុនថាអ៊ុំចង់គិតធ្វើអីមួយអ៊ុំធ្លាប់ប្រាប់ពួកគាត់ដើម្បីអោយពួកគាត់អាចធ្វើតាមអ្វីដែរអ៊ុំព្រានប្រដៅពួកគាត់ទេអ៊ុំ?

ខ៖ ប្រាប់តើប៉ុនវាអត់ស្តាប់។

ក៖ កូនៗរបស់អ៊ុំអីចៅៗរបស់អុំអី?

ខ៖ ចាស! ប្រាប់ហ្នឹងហាសវាអត់ស្តាប់អត់តាមផងមិនដឹងធ្វើម៉េច។

ក៖ ចឹងហោសអ៊ុំ?

ខ៖ ចាស!

កៈ អូ៎!

ខៈ ប្រដៅប្រដៅវាអោយតែមកប្រដៅៗបើវាអត់ស្តាប់អត់តាម។

កៈ អូ៎ទាំងកូនទាំងចៅទាំងអស់?

ខៈ ចាស!

កៈ តែចៅៗពីរហ្នឹងប្រាប់ទាំងអស់ដែរណេះ?

ខៈ ចាស! ប្រាប់ហ្នឹង!

កៈ ពួកគាត់ចេះតែធ្វើតាមយើងចៅៗ?

ខៈ ចាស!

កៈ អូ៎ល្អអ៊ុំចុះអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្តាំផ្ញើរពីនិងទៅចៅៗផ្សេងទៀតអត់អ៊ុំអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្តាំផ្ញើរទៅចៅៗឬមួយក៏ទូន្មានអីផ្សេងពីនិងទៀតអត់?

ខៈ ឲចៅៗជំនាន់ក្រោយនិងអោយចេះដឹងជាជំនាន់មុន។

កៈ អូ៎ប៉ុណ្ណឹងទេណេះអ៊ុំណេះ?

ខៈ ចាស!

កៈ អូ៎ចឹងចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពីភាក្សាជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំហើយខ្ញុំនិងដាក់ការសម្ភាសទាំងអស់និងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយកូនចៅជំនាន់ៀក្រោយរបស់អ៊ុំបានស្គាល់បានដឹងពីប្រវត្តិរបស់អ៊ុំដែរអ៊ុំបានរៀបរាប់ចឹងហាសណាស់ចឹងចុងក្រោយខ្ញុំសុំការអនុញ្ញាតិពីអ៊ុំដើម្បីដាក់ការសម្ភាសមួយនិងទៅក្នុងវេបសាយសាលាបានទេអ៊ុំ?

ខៈ ចាស!

កៈ បាទអ៊ុំបាទចឹងអរគុណច្រើនណាស់អ៊ុំ។